ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# ឯកសារស្រាវជ្រាវគំរូ
# បច្ចេកទេសចិញ្ចឹមត្រីកាបសក្នុងស្រះ
## Silver Carp Raising in Pond




រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**


ខែវិច្ឆិកា ឆ្នាំ២០២៣

# អារម្ភកថា

ត្រីកាបស ត្រូវបានកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០១១ ជាប្រភេទត្រីដែលនឹងឈានទៅដល់ការផុតពូជ។ ការនេសាទហួសកម្រិត ការបំពុលបរិស្ថាន ការបាត់បង់ទីជម្រក គឺជាបញ្ហាអវិជ្ជមានប៉ះពាល់ដល់ជីវិតមច្ឆាប្រភេទនេះ។ បញ្ហាប្រឈមទាំងអស់បានជំរុញឱ្យមានការផ្លាស់ប្ដូរ ដោយកាត់បន្ថយការនេសាទត្រីពីធម្មជាតិ និងពីការចិញ្ចឹមត្រីសម្រាប់តែជាអាហារប្រចាំគ្រួសារ ទៅជាការចិញ្ចឹមសម្រាប់ផ្គត់ផ្គង់ទីផ្សារ។

ដើម្បីរួមចំណែកអភិវឌ្ឍន៍វិស័យវារីវប្បកម្មកម្ពុជា ក៏ដូចជាជួយដល់កសិករដែលចិញ្ចឹមត្រីកាបសទទួលបាននូវចំណេះដឹងបច្ចេកទេសបន្ថែមសម្រាប់កែលម្អចំណុចខ្វះខាត និងបញ្ហាប្រឈមនានា ធ្វើឱ្យអាជីវកម្មចិញ្ចឹមត្រីកាបសទទួលបានលទ្ធផលល្អប្រសើរ ក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី) បានសិក្សាស្រាវជ្រាវរៀបចំឯកសារ **គំរូបច្ចេកទេសចិញ្ចឹមត្រីកាបសក្នុងស្រះ** ដោយចុះសិក្សាពីបទពិសោធន៍នៃការអនុវត្តជាក់ស្តែងរបស់កសិករចិញ្ចឹមត្រីកាបសផ្ទាល់នៅតាមមូលដ្ឋាន និងសិក្សាពីឯកសារបច្ចេកទេសនានាជាច្រើនស្ដីពី វិធីសាស្ត្រចិញ្ចឹមត្រីកាបសប្រកបដោយជោគជ័យមួយចំនួននៅក្នុងប្រទេសនិងប្រទេសជិតខាង។ ឯកសារនេះបង្ហាញនូវបណ្តុំបច្ចេកទេសសំខាន់ៗ ពាក្យពេចន៍សាមញ្ញ និងមានរូបភាពដើម្បីបង្ហាញជូនអ្នកអាន ក៏ដូចជាកសិករងាយយល់ ងាយអនុវត្តន៍។ ក្រុមការងារសង្ឃឹមថា ឯកសារគំរូបច្ចេកទេសនេះនឹងអាចបំពេញចន្លោះខ្វះខាតលើបច្ចេកទេសចិញ្ចឹមត្រីកាបស ឬចិញ្ចឹមត្រីចម្រុះរបស់កសិករ ឈានពីការចិញ្ចឹមបែបលក្ខណៈគ្រួសារទៅជារបរអាជីវកម្មមួយច្បាស់លាស់។

ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមកសិករចិញ្ចឹមត្រីកាបស ដែលបានផ្តល់ឱកាសដល់ក្រុមការងារបានជួបសិក្សាដកស្រង់បទពិសោធន៍ពីភាពជោគជ័យ និងបញ្ហាប្រឈមនានាលើអាជីវកម្មចិញ្ចឹមត្រីកាបស ព្រមទាំងបានផ្តល់នូវធាតុចូលសំខាន់ៗជាច្រើនសម្រាប់ការងារចងក្រងឯកសារស្រាវជ្រាវ **គំរូបច្ចេកទេសចិញ្ចឹមត្រីកាបសក្នុងស្រះ** នេះ។ យើងខ្ញុំរង់ចាំទទួលនូវមតិកែលម្អពីសំណាក់ប្រជាកសិករ អ្នកស្រាវជ្រាវកសិកម្ម និងអ្នកជំនាញវារីវប្បកម្មទាំងអស់ ដើម្បីឱ្យការរៀបចំឯកសារលើកក្រោយៗកាន់តែមានភាពល្អប្រសើរថែមទៀត ដើម្បីជាប្រយោជន៍ដល់កសិករ។

សូមអរគុណ !

# មាតិកា

១-សេចក្តីផ្តើម....................1
២-លក្ខណៈជីវសាស្ត្ររបស់ត្រីកាបស....................1
២.១. លក្ខណៈសរីរាង្គ....................2
២.២. មជ្ឈដ្ឋានទឹក....................2
២.៣. ចរិតស៊ីចំណី....................3
២.៤. ការលូតលាស់....................3
២.៥. ការបន្តពូជ....................4
៣-បច្ចេកទេសចិញ្ចឹមត្រីកាបសក្នុងស្រះ....................5
៣.១. ការជ្រើសរើសទីតាំង និងការជីកស្រះ....................5
៣.២. ការរៀបចំស្រះមុនពេលដាក់កូនត្រី....................6
៣.៣. ការជ្រើសរើសកូនត្រីពូជ....................8
៣.៤. ដង់ស៊ីតេដាក់ត្រីចិញ្ចឹម....................8
៣.៥. ការលែងកូនត្រីពូជ....................9
៣.៦. ប្រភេទចំណី និងការផ្តល់ចំណី....................10
ក- ប្រភេទចំណី....................10
ខ- ការផ្តល់ចំណី....................11
៣.៧. ការគ្រប់គ្រង និងថែទាំ....................13
ក- គ្រប់គ្រងលើគុណភាពទឹក....................13
ខ- តាមដានការលូតលាស់របស់ត្រី....................14
៣.៨. ការបង្ការ និងការព្យាបាលជំងឺ....................14
៣- ៩- ការប្រមូលផល....................17
៤-សេចក្តីសន្និដ្ឋាន....................18
ប្រភពឯកសារបានសិក្សាស្រាវជ្រាវ....................19

## ១-សេចក្តីផ្តើម

វិស័យវារីវប្បកម្ម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមផ្គត់ផ្គង់ម្ហូបអាហារសម្រាប់ជីវភាពរស់នៅប្រកបដោយនិរន្តភាព និងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបរិស្ថាន។ ការចិញ្ចឹមត្រីកាបសនៅក្នុងប្រទេសកម្ពុជាភាគច្រើនគឺចិញ្ចឹមជាលក្ខណៈគ្រួសារតាមបែបពាក់កណ្តាលប្រពលវប្បកម្ម និងប្រពលវប្បកម្ម ដោយដាក់ចិញ្ចឹមចម្រុះរវាងត្រីកាបស ជាមួយប្រភេទត្រីផ្សេងទៀត មានដូចជា ត្រីកាបសាមញ្ញ កាបឥណ្ឌា កាបស៊ីស្មៅ ឆ្ពិន ត្រីទីឡាព្យា ជាដើម។ ការដាក់កូនត្រីចិញ្ចឹមចម្រុះបែបនេះ កសិករអាចប្រើប្រាស់ចំណី ធម្មជាតិមាននៅក្នុងស្រះ និងចំណីផ្តល់បន្ថែមដើម្បីឱ្យត្រីធំធាត់បានលឿន។

ត្រីកាបស ជាប្រភេទត្រីងាយស្រួលក្នុងការចិញ្ចឹម ដោយស៊ីប្រភេទរុក្ខជាតិប្លង់តុងជាចម្បង លូតលាស់ធំលឿន ធន់នឹងជំងឺ ហើយអាចផលិតកូនពូជបាននៅតាមកសិដ្ឋាន និងមានតម្រូវការនៅលើទីផ្សារខ្ពស់។ ដើម្បីបង្កើនផលិតភាពផលិតកម្មចិញ្ចឹមត្រីកាបស អ្នកចិញ្ចឹមត្រូវធ្វើការកែលម្អនូវវិធីសាស្ត្រចិញ្ចឹមមួយចំនួនដូចជា÷ ជ្រើសរើសទីតាំងឱ្យបានសមស្រប រៀបចំស្រះឱ្យបានត្រឹមត្រូវ ការជ្រើសរើសកូនត្រីពូជឱ្យបានល្អមានប្រភពច្បាស់លាស់ ផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងអនាម័យការគ្រប់គ្រងថែទាំត្រី ជាពិសេសការការពារ និងការព្យាបាលជំងឺសមស្របតាមស្តង់ដារសុវត្ថិភាពឱ្យបានត្រឹមត្រូវ ។

## ២-លក្ខណៈជីវសាស្ត្ររបស់ត្រីកាបស

ត្រីកាបសមានឈ្មោះវិទ្យាសាស្ត្រ Hypophthalmichthys molitrix ស្ថិតក្នុងអម្បូរត្រីកាប Cyprinidae ។ ត្រីកាបស ជាត្រីទឹកសាបមានស្រកាមួយប្រភេទមានដើមកំណើត និងរស់នៅពាសពេញអាងទន្លេហីឡុងជាំង ទន្លេយ៉ាងសេ និងទន្លេភៀល (Heilongjiang, Yangtze and Pearl) ក្នុងប្រទេសចិន។ កាបសជាប្រភេទត្រីអាស៊ី រស់នៅភាគខាងកើតស៊ីបេរីចាប់ពីភាគខាងជើងទន្លេអាមួរ(Amur) ប្រទេសរុស្ស៊ីរហូតដល់ភាគខាងត្បូងទន្លេ Xi Jiang និងប្រទេសម៉ុងហ្គោលី។ ត្រីកាបស ត្រូវបានផ្សព្វផ្សាយទៅកាន់ជាង ៨៨ប្រទេសជុំវិញពិភពលោក ដោយហេតុផលសម្រាប់អភិវឌ្ឍន៍វិស័យវារីវប្បកម្ម ពង្រឹងការគ្រប់គ្រងធនធានត្រីធម្មជាតិ និងការគ្រប់គ្រងគុណភាពទឹក។

**ឈ្មោះជាភាសាខ្មែរ÷ ត្រីកាបស**

**ឈ្មោះជាភាសាអង់គ្លេស÷ Silver Carp**

**ឈ្មោះវិទ្យាសាស្ត្រ÷ Hypophthalmichthys molitrix**




### ២.១. លក្ខណៈសរីរាង្គ÷

ត្រីកាបស (Hypophthalmichthys molitrix) ជាប្រភេទត្រីស្រកាល្អិត មានប្រវែងដងខ្លួនអតិបរមា ៧០ស.ម និងទម្ងន់ ៥០គ.ក។ ត្រីមានដងខ្លួនវែងសំប៉ែតសម្បុរប្រាក់ ក្បាលធំមិនមានស្រកា ភ្នែកស្ថិតនៅខាងក្រោមនៃផ្នែកក្បាលខិតនៅមុខ បបូរមាត់ខាងក្រោមវែងជាងបបូរមាត់ខាងលើ ទ្រនុងពោះសណ្ឋានដូចមុខកាំបិតចាប់ពីកដល់រន្ធគូទ មានព្រុយខ្នង០១ ព្រុយថ្ពាល់ចំហៀង០២ ព្រុយពោះ០៣ និងកន្ទុយរៀងអក្សរវី (V) ដែលមានភាពរឹងមាំ អាចបង្កគ្រោះថ្នាក់ដល់អ្នកចាប់បើមិនមានការប្រយ័ត្ន។ ត្រីកាបស មានក្រពេញបញ្ចេញសារធាតុអាមីន(Amin)ពីសារពាង្គកាយនាំឱ្យត្រីមានក្លិនឆ្អាបខ្លាំង។ យើងអាចសម្គាល់ត្រីកាបសបាន តាមរយៈការហែលប៉ប្រះទឹក និងសកម្មភាពដ៏រស់រវើកនៃទម្លាប់លោតចេញពីទឹក នៅពេលមានការរំខាន ឬមានអ្វីធ្វើឱ្យភ្ញាក់ផ្អើល។



**២.២. មជ្ឈដ្ឋានទឹក÷**

ត្រីកាបស ជាប្រភេទត្រីទឹកសាបរស់នៅផ្ទៃទឹកកណ្តាលផ្នែកខាងលើ ជាប្រភេទទឹកនឹងឬមានចរន្តហូរខ្សោយដូចជា ទន្លេ បឹងបួរ ព្រែក អូរ និងអាងស្តុកទឹកជាដើម។ ទោះបីជាត្រីកាបស អាចបន្សុំខ្លួនរស់នៅក្នុងសីតុណ្ហភាពទឹកទាបពី ៦អង្សាសេ ដល់ ៤០អង្សាសេ ប៉ុន្តែ បានប៉ះពាល់ដល់កម្រិតនៃការលូតលាស់ ការចាប់ចំណី ការរំលាយអាហារ និងសកម្មភាពជីវសាស្ត្រផ្សេងទៀតរបស់ត្រីផងដែរ។ ពេលសីតុណ្ហភាពទឹកធ្លាក់ក្រោម ១៥អង្សាសេ ការចាប់ចំណីរបស់ត្រីធ្លាក់ចុះ ឬបញ្ឈប់ការចាប់ចំណីនៅសីតុណ្ហភាពពី ៧-៨ អង្សាសេ។ សីតុណ្ហភាពសមស្របបំផុតសម្រាប់ការលូតលាស់គឺចន្លោះពី ២៧-៣២អង្សសេ។

ទោះបីជាត្រីកាបស អាចទ្រាំបាននឹងការប្រែប្រួលកម្រិត pH ខ្លាំងក៏ដោយ ប៉ុន្តែស្ថិតក្នុងពេលវេលាមួយកំណត់ប៉ុណ្ណោះ។ ត្រីនឹងស្លាប់ពេលកម្រិត pH តូចជាង៤ឬធំជាង១០.២។ ករណីកម្រិត pH តូចជាង៦ ឬធំជាង ៨.៥ ធ្វើឱ្យកម្រិតអុកស៊ីសែន និងប្រព័ន្ធភាពសមចុះខ្សោយ នាំឱ្យត្រីមានការលូតលាស់យឺត។ នៅក្នុងវារីវប្បកម្មកម្រិត pH ដែលសម្របស្របបំផុតចន្លោះពី ៦.៥-៨.៥។

លើសពីនេះ កម្រិតនៃការលូតលាស់ និងការស៊ីចំណីរបស់ត្រីក៏អាស្រ័យលើកម្រិតអុកស៊ីសែនរលាយក្នុងទឹក(DO)ផងដែរ។ ពេលកម្រិត DO ធំជាង ២.២មីលីក្រាម/លីត្រទឹក ត្រីមានការលូតលាស់ និងធំធាត់ធម្មតា ប៉ុន្តែពេលកម្រិត DO តូចជាង ២មីលីក្រាម/លីត្រទឹក ការចាប់ចំណីឬស៊ីចំណីរបស់ត្រីថយចុះ។

កម្រិតDO តូចជាង១.១មីលីក្រាម/លីត្រទឹក ត្រីចាប់ផ្តើមងើបឡើងលើផ្ទៃទឹក និងស្លាប់នៅពេលកម្រិតDO តូចជាង ០.៣៥មីលីក្រាម/លីត្រទឹក។

### ២.៣. ចរិតស៊ីចំណី÷

ត្រីកាបសស៊ីរុក្ខជាតិប្លង់តុង (Phytoplankton) ជាចម្បងពោលគឺពពួករុក្ខជាតិនៅក្នុងទឹក ដែលកើតចេញពីរុក្ខជាតិរលួយ និងសត្វប្លង់តុង (Zooplankton) ដែលកើតចេញពីសត្វរលួយ។ ក្រោយពេលញាស់បានអាយុ ១-២ថ្ងៃ កូនត្រីមានប្រវែង ៧-៩មីលីម៉ែត្រ ប្រវែងពោះវៀនស្មើនឹង ៥០-៦០%នៃប្រវែងដងខ្លួនត្រី ដែលកូនត្រីចាប់ផ្តើមស៊ីចំណីប្រភេទសត្វប្លង់តុង (Rotiferal, Copepoda...)។ នៅពេលកូនត្រីលូតលាស់បានប្រវែងពី៣០មីលីម៉ែត្រ ស្រកីរបស់ត្រីបានលូតលាស់ពេញលេញមានតួនាទីជាឧបករណ៍ចម្រោះមួយ និងចាប់ផ្តើមស៊ីប្រភេទរុក្ខជាតិប្លង់តុង និងរុក្ខជាតិទឹកផ្សេងៗជាចម្បង។ ត្រីកាបសពេញវ័យមានពោះវៀនប្រវែងស្មើនឹង ៦.៨៥ដងនៃប្រវែងដងខ្លួនត្រី និងចំណីចម្បងគឺប្រភេទរុក្ខជាតិទឹក(៦០%) បន្ទាប់មកមានសត្វប្លង់តុង សត្វល្អិតក្នុងទឹក និងក្រៅពីនេះមានប្រភេទកាកសំណល់សរីរាង្គរលួយ។




### ២.៤. ការលូតលាស់÷

ត្រីកាបស មានកម្រិតលូតលាស់លឿន ដោយនៅក្នុងធម្មជាតិត្រីអាយុ១ឆ្នាំមានទម្ងន់ចន្លោះពី ០.៧-០.៩គ.ក/ក្បាល អាយុ ០២ឆ្នាំ មានទម្ងន់ចន្លោះពី ១.៤-១.៨គ.ក/ក្បាល អាយុ ០៤ឆ្នាំ មានទម្ងន់ពី ៤-៥.៥គ.ក/ក្បាល ដោយត្រីញីធំជាងត្រីឈ្មោល និងអាចរស់បានដល់អាយុ ២០ឆ្នាំ។ ក្នុងលក្ខខណ្ឌចិញ្ចឹមក្នុងស្រះតាមបច្ចេកទេស ក្នុង១ឆ្នាំត្រីអាចមានទម្ងន់ពី ១-១.៥គ.ក/ក្បាល ចិញ្ចឹម០២ឆ្នាំ អាចមានទម្ងន់ពី ២-៣គ.ក/ក្បាល និងក្រោយ០៣ឆ្នាំ អាចមានទម្ងន់ពី ៤-៥គ.ក/ក្បាល។

***តារាងទី១-ការលូតលាស់ប្រចាំខែរបស់ត្រីកាបសអាស្រ័យលើដំណាក់កាលទម្ងន់ត្រី÷***

| ដំណាក់កាលទម្ងន់ត្រី (គ.ក/ក្បាល) | ការឡើងទម្ងន់ប្រចាំខែ (គ.ក/ក្បាល/ខែ) |
|---|---|
| 0.05 -0.25 | 0.1 -0.2 |
| 0.3 -0.5 | 0.2-0.25 |
| 0.5-2 | 0.3-0.4 |
| 2-4 | 0.08-0.2 |

*ប្រភព÷ Zong Lin, 1991. Pond fisheries in China*

តារាងទី១ បង្ហាញថា នៅដំណាក់កាលកូនត្រីមានទម្ងន់ពី ០.០៥-០.៥គ.ក/ក្បាល ត្រីមានកម្រិតលូតលាស់ពី ០.១-០.២គ.ក/ខែ និងនៅដំណាក់កាលត្រីមានទម្ងន់ពី ០.៥-២គ.ក/ក្បាល ត្រីលូតលាស់លឿនពី ០.៣-០.៤គ.ក/ខែ ក្រោយមកចាប់ផ្តើមយឺតបន្តិចវិញក្រោយពេលត្រីទម្ងន់២គ.ក/ក្បាល។ ប៉ុន្តែ បើសិនជាការចិញ្ចឹមរបស់កសិករមិនបានត្រឹមត្រូវ មានដង់ស៊ីតេខ្ពស់ ចំណីមិនគ្រប់គ្រាន់ គុណភាពទឹកមិនបានល្អ ត្រីអាចបានទម្ងន់ត្រឹមតែ ០.១-០.២គ.ក/ក្បាលប៉ុណ្ណោះ ក្នុងការចិញ្ចឹមរយៈពេល១ឆ្នាំ។

***តារាងទី២-ការលូតលាស់ប្រចាំឆ្នាំរបស់ត្រីកាបសនៅក្នុងធម្មជាតិ***

| អាយុ (ឆ្នាំ) | ប្រវែងកូនត្រី (សង់ទីម៉ែត្រ/ក្បាល) | ទម្ងន់ត្រី (គ.ក/ក្បាល) |
|---|---|---|
| 1 | 15 | 0.67 |
| 2 | 50 | 1.87 |
| 3 | 57 | 4.56 |
| 4 | 60.3 | 5.34 |
| 5 | 63 | 6.40 |



## ២.៥. ការបន្តពូជ÷

លក្ខណៈធម្មជាតិរបស់ត្រីកាបស មិនមានសមត្ថភាពបន្តពូជនៅក្នុងស្រះចិញ្ចឹមបានទេ។ ត្រីនឹងធ្វើការផ្លាស់ទីទៅខ្សែទឹកខាងលើដើម្បីបង្កាត់ពូជ និងពងកូន។ បន្ទាប់មកពងរបស់វាបានញាស់នៅទីនោះ និងអណ្តែតតាមខ្សែទឹកចូលទៅក្នុងតំបន់ទំនាបលិចទឹក ដៃទន្លេ ស្ទឹង បឹងបួរ អាងស្តុកទឹក ដែលជាកន្លែងសម្បូរចំណីធម្មជាតិធ្វើឱ្យកូនត្រីលូតលាស់ធំធាត់លឿន។ ត្រីកាបសញី អាយុ៣ឆ្នាំ និងត្រីឈ្មោលអាយុ២ឆ្នាំ អាចបង្កាត់ពូជបាន ដោយមុនដល់រដូវបន្តពូជត្រីចាប់ផ្តើមប្រមូលផ្តុំជាហ្វូង និងធ្វើការបន្លាស់ទីតាមខ្សែទឹកឡើងទៅផ្នែកខាងលើដើម្បីបន្តពូជ និងពងកូន។ រដូវបន្តពូជត្រីកាបសចាប់ពីខែឧសភា ដល់កក្កដា ប៉ុន្តែនៅក្នុងការបង្កាត់ភ្ញាស់សិប្បនិម្មិតអាចអនុវត្តន៍លឿនជាងចាប់ពីចុងខែមីនា និងអាចបង្កាត់ភ្ញាស់ច្រើនដងក្នុង១ឆ្នាំ ដោយប្រើថ្នាំអ័រម៉ូន (HCG) ជំរុញ និងបង្កើតលក្ខខណ្ឌ (ចរន្តទឹក សីតុណ្ហភាព) ប្រហាក់ប្រហែលទៅនឹងបរិស្ថានធម្មជាតិ ដើម្បីជំរុញឱ្យត្រីបង្កាត់ពូជ។

*តារាងទី៣-ការបង្កាត់ពូជរបស់ត្រីកាបស*

| ទម្ងន់ត្រីញី (គ.ក) | ទម្ងន់កន្សោមពង (គ.ក) | ចំនួនគ្រាប់ពងក្នុង១ក្រាម | ចំនួនកូនត្រីបានញាស់ជាមធ្យម | ផលធៀបកន្សោមទៅនិងទម្ងន់ត្រី (%) |
|---|---|---|---|---|
| 4.8 | 0.25 | 828 | 207,000 | 5.2 |
| 6.4 | 0.74 | 816 | 604,000 | 11.5 |
| 7.5 | 0.71 | 1,007 | 715,000 | 9.5 |
| 10 | 2.13 | 796 | 1,695,000 | 21.3 |
| 11 | 2.13 | 912 | 1,777,000 | 19.3 |



**៣-បច្ចេកទេសចិញ្ចឹមត្រីកាបសក្នុងស្រះ ÷**

ត្រីកាបសជាប្រភេទត្រីក្នុងស្រុក ងាយស្រួលក្នុងការចិញ្ចឹម ពីព្រោះត្រីមានភាពធន់នឹងជំងឺ មានការលូតលាស់លឿន ស៊ីចំណីចម្រុះច្រើនប្រភេទដូចជា ÷បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួន កន្ទក់ ចុងអង្ករ ពោតសណ្តែក កាកសំណល់ផ្ទះបាយ។ បច្ចុប្បន្ន ការចិញ្ចឹមត្រីកាបសក្នុងស្រះមានរូបភាពខុសៗគ្នាអាស្រ័យលើស្ថានភាពតំបន់ ទីផ្សារ និងសមត្ថភាពរបស់កសិករ ក្នុងនោះរួមមាន÷ ការចិញ្ចឹមតាមបែបលក្ខណៈគ្រួសារពាក់កណ្តាលប្រពលវប្បកម្ម ឬប្រពលវប្បកម្ម ឬតាមបែបឧស្សាហកម្ម។

ទោះបីការចិញ្ចឹមជាលក្ខណៈគ្រួសារតាមបែបពាក់កណ្តាលប្រពលវប្បកម្ម ឬប្រពលវប្បកម្មក្តី វារីវប្បករចាំបាច់ត្រូវធ្វើការស្វែងយល់ចំណុចសំខាន់ៗនៃបច្ចេកទេសក្នុងការចិញ្ចឹមដូចខាងក្រោម÷

**៣.១. ការជ្រើសរើសទីតាំង និងការជីកស្រះ÷**

- ស្រះចិញ្ចឹមត្រីត្រូវមានប្រភពទឹកស្អាតគ្រប់គ្រាន់ ងាយស្រួលក្នុងការបញ្ចូល និងបញ្ចេញទឹក
- ជ្រើសរើសទីតាំងស្ងប់ស្ងាត់ ជៀសវាងមានសម្លេងរំខាន (ដោយសារជាប្រភេទត្រីងាយផ្អើល)
- ដីមានកម្រិតជ្រាបទឹកតិចឬបាតស្រះជាប្រភេទដីឥដ្ឋឬដីកណ្តោង អាចផ្ទុកទឹកបានយ៉ាងតិច៨ខែ
- នៅឆ្ងាយពីតំបន់ដែលកសិករប្រើថ្នាំពុលគីមីកសិកម្ម និងប្រភពពុលផ្សេងៗទៀត
- នៅទីវាលដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ (គ្មានដើមឈើធំៗនៅជុំវិញ)
- ស្រះគួរមានផ្ទៃទឹកចាប់ពី ១,០០០ម៉ែត្រការ៉េ មានជម្រៅទឹកជាង ១.៥-២ម៉ែត្រ
- ជីកស្រះរាងចតុកោណកែង ទទឹងស្រះពី ៣០-៥០ម ដើម្បីងាយស្រួលអូសចាប់ត្រី

- កម្ពស់ភ្លឺស្រះពី ០.៦-០.៨ម និងស្រះមានជើងទេរ
- បាតស្រះរាបស្មើ និងជម្រាលទៅផ្នែកម្ខាងនៃស្រះ
- ជីកយកដីស្រែស្រទាប់លើធ្វើជាទំនប់ព័ទ្ធជុំវិញស្រះការពារច្រោះនូវកាកសំណល់ និងដីឥដ្ឋទុកទ្រាប់បាតស្រះ។
- នៅតាមច្រាំងស្រះគួរបង្កប់បំពង់សម្រាប់បង្ហូរទឹកចូលស្រះ



## ៣.២. ការរៀបចំស្រះមុនពេលដាក់កូនត្រី÷

### ក/-ការរៀបចំស្រះចាស់÷

- បូមទឹកពង្រីងឱ្យអស់ពីបាតស្រះ
- សម្អាតកំណាត់ឈើ ថង់ផ្លាស្ទិច និងសំរាមផ្សេងៗដែលមាននៅក្នុងស្រះ
- កាប់ឆ្ការព្រៃ និងស្មៅនៅជុំវិញមាត់ស្រះ
- កម្ចាត់សត្វចង្រៃដូចជា កង្កែប ក្តាម ពស់ និងត្រីកាច (ត្រីផ្ទក់ និងឆ្តោ) ចេញពីស្រះ
- ជួសជុលទំនប់ ច្រាំង ជើងទេរ និងបាតស្រះឱ្យបានរឹងមាំឡើងវិញ
- ស្តារភក់ដោយទុកត្រឹមតែ ០.២-០.៣ម៉ែត្រ ដោយពង្រាបបាតស្រះឱ្យស្មើ និងទេរទៅផ្នែកម្ខាង
- បាចកំបោរកសិកម្មបរិមាណពី ៧-១០គ.ក/១០០ម$^{២}$
- ហាលស្រះរយៈពេលពី ២-៥ថ្ងៃ ដើម្បីកាត់បន្ថយជាតិជូរឬប្រៃ កម្ចាត់សត្វចង្រៃ សម្លាប់មេរោគ ធ្វើឱ្យទឹកងាយថ្លា និងចំណីធម្មជាតិងាយកើតមាន។
- ហ៊ុំស្បៃជុំវិញស្រះ ដើម្បីការពារត្រីព្រៃ និងសត្វចង្រៃខាងក្រៅចូល និងត្រីខាងក្នុងចេញពីស្រះ
- ដាក់ជីលាមកសត្វដូចជា លាមកគោ ក្របី មាន់ ទា រុក្ខជាតិបៃតង (ដើមទន្ទ្រានខែត្រស្រស់) ÷
    - លាមកគោឬក្របី ÷ ៨០-១០០គ.ក/១០០ម$^{២}$
    - លាមកមាន់ ទា (បើមាន) ÷ ១៥-២០គ.ក/១០០ម$^{២}$
    - ដើមទន្ទ្រានខែត្រ (ចងជាបាច់) ÷ ៣០-៤០គ.ក/១០០ម$^{២}$
- ក្រោយពីដាក់ជីទ្រាប់បាតស្រះរួចបញ្ចូលទឹកក្នុងស្រះ ជម្រៅទឹក ០.៥ម៉ែត្រ ហើយរក្សាទឹកពី ៣-៥ថ្ងៃ ឬ១សប្តាហ៍។

- ចុងក្រោយបន្ថែមទឹកចូលស្រះតាមតម្រូវការ។ ក្រោយពី៤-៥ថ្ងៃ បើសង្កេតឃើញទឹកមានពណ៌បៃតង មានន័យថាចំណីធម្មជាតិកើតមាន និងអាចដាក់កូនត្រីចិញ្ចឹមបាន។

**ខ/-ការរៀបចំស្រះថ្មី÷**

- យកដីស្រែទាប់លើដាក់បាតស្រះ រួចបញ្ចូលទឹកឱ្យលិចដីបាតស្រះបន្តិច ហើយត្រាំទុកពី ៣-៤ ថ្ងៃ បង្កើតភក់ខ្លះៗ ដើម្បីងាយកើតចំណីធម្មជាតិ ក្រោយពីដាក់លាមកសត្វ និងរុក្ខជាតិបៃតង។
- បន្ទាប់មកបូមទឹកចេញ រួចបាចកំបោរកសិកម្មភ្លាមពី ១០-១៥គ.ក/១០០ម២ នៃផ្ទៃស្រះ ដើម្បីឱ្យកំបោរមានប្រតិកម្មជាមួយភក់។
- ហាលបាតស្រះពី ១-២ថ្ងៃ ដើម្បីកាត់បន្ថយជាតិជូរឬប្រៃនៅក្នុងស្រះ ធ្វើឱ្យទឹកងាយថ្លា និងងាយបង្កើតចំណីធម្មជាតិ។
- ហ៊ុំស្បៃជុំវិញស្រះ ដើម្បីការពារត្រីព្រៃ និងសត្វចង្រៃខាងក្រៅចូល និងត្រីខាងក្នុងចេញពីស្រះ
- បន្ទាប់មកដាក់ជីលាមកសត្វ និងរុក្ខជាតិស្រស់ (ដូចបរិមាណខាងលើ)
- បញ្ចូលទឹកក្នុងស្រះឱ្យបានកម្ពស់ទឹក ០.៥ម៉ែត្រ ហើយត្រាំទុកពី៣-៥ថ្ងៃ ឬ១សប្តាហ៍ ដើម្បីបង្កើតចំណីធម្មជាតិ។
- ចុងក្រោយបន្ថែមទឹកចូលស្រះតាមតម្រូវការ។ ក្រោយពី ៤-៥ថ្ងៃ បើសង្កេតឃើញទឹកមានពណ៌បៃតង មានន័យថាចំណីធម្មជាតិកើតមាននៅក្នុងស្រះ និងអាចដាក់កូនត្រីចិញ្ចឹមបាន។



***សម្គាល់÷*** ប្រសិនជាប្រើជីគីមីដើម្បីបង្កើតចំណីធម្មជាតិ គឺប្រើក្នុងករណីទឹកមិនទាន់មានពណ៌បៃតងល្អ ដោយប្រើប្រភេទជីអ៊ុយរ៉េ (URE) និងជីដេអាប៉េ (DAP) លាយបញ្ចូលគ្នាកូរឱ្យរលាយសព្វក្នុងទឹកធុងបន្ទាប់មកយកទៅបាចពេញផ្ទៃស្រះពេលថ្ងៃក្តៅទើបមានប្រសិទ្ធភាព។ រយៈពេល៤-៥ថ្ងៃក្រោយទឹកមានពណ៌បៃតង ឬពណ៌ត្រួយចេក (ចំណីធម្មជាតិកើត) ទើបអាចលែងកូនត្រីបាន។ ការប្រើប្រាស់ជីមានដូចខាងក្រោម÷

- ប្រើជីអ៊ុយរ៉េ (UREA) ÷ ៣ក្រាម/ម$^{២}$
- ប្រើជីដេអាប៉េ (DAP) ÷ ២ក្រាម/ម$^{២}$






### ៣.៣. ការជ្រើសរើសកូនត្រីពូជ÷

ដើម្បីទទួលបានទិន្នផលខ្ពស់ និងមានអត្រាបាត់បង់តិច កសិករចិញ្ចឹមត្រីត្រូវធ្វើការជ្រើសរើសកូនត្រីពូជឱ្យបានត្រឹមត្រូវ ដែលមានលក្ខណៈសំខាន់ៗដូចខាងក្រោម÷

- កូនត្រីពូជផលិតក្នុងស្ថានីយ ឬកសិដ្ឋានដែលអាចទុកចិត្តបាន មានកេរ្តិ៍ឈ្មោះល្អ មានការកត់ត្រាច្បាស់លាស់ ត្រីមេបាពូជល្អ និងរៀបចំបានស្អាត។
- កូនត្រីពូជមានប្រវែងពី ៥-៨ សង់ទីម៉ែត្រ/ក្បាល ឬទម្ងន់ពី ៣០០-៥០០ក្បាល/គ.ក
- មានទំហំប៉ុនៗគ្នា ឬប្រហាក់ប្រហែលគ្នា
- មានសុខភាពល្អ ÷ មានកម្លាំងមាំមួន រហ័សរហួន ពណ៌សម្បុរស្រស់ថ្លា
- គ្មានរបួសស្នាម ឬដំបៅលើដងខ្លួន មានរូបរាងស្អាត
- គ្មានផ្នែកណាមួយខុសប្រក្រតី





### ៣.៤. ដង់ស៊ីតេដាក់ត្រីចិញ្ចឹម÷

កម្រិតនៃការដាក់កូនត្រីពូជចិញ្ចឹមសមស្របបំផុតចន្លោះពី ១០,០០០-១៤,០០០ក្បាល/១ហិកតា ឬចន្លោះពី ១-១.៤ក្បាល/ម$^{២}$។ តាមរយៈបទពិសោធន៍ជាក់ស្តែង ការដាក់ចិញ្ចឹមត្រីកាបសរួមផ្សំជាមួយប្រភេទត្រីផ្សេងទៀត ដូចជាត្រីកាបសាមញ្ញ កាបឥណ្ឌា កាបស៊ីស្មៅ កាបក្បាលធំ ឆ្ពិន និងត្រីទីឡាព្យា បានផ្តល់ទិន្នផលខ្ពស់ជាងការដាក់ចិញ្ចឹមទោលត្រីកាបសតែមួយប្រភេទ ពីព្រោះការចិញ្ចឹមត្រីចម្រុះដែលមានចរិតស៊ីចំណី និងរស់នៅស្រទាប់ទឹកខុសគ្នានៅក្នុងស្រះតែមួយធ្វើឱ្យត្រីអាចប្រើប្រាស់ចំណីអស់ពីលទ្ធភាព (ទាំងចំណីធម្មជាតិដែលមាននៅក្នុងស្រះ និងចំណីដែលបានផ្តល់) និងបង្កាជំងឺបានខ្ពស់ជាងការចិញ្ចឹមទោល ជួយជំរុញឱ្យត្រីមានការធំធាត់ និងលូតលាស់លឿន។ ទោះជាយ៉ាងនេះក្តីក្នុងដំណើរការចិញ្ចឹម

កសិករត្រូវគោរពតាមលក្ខខណ្ឌបច្ចេកទេសមួយចំនួនដូចជា÷ បរិមាណ គុណភាព ទីតាំងផ្តល់ចំណី និង ពេលវេលាផ្តល់ចំណីឱ្យបានល្អ។

***តារាងទី៤- រូបមន្តនៃការចិញ្ចឹមចម្រុះមួយចំនួនសម្រាប់កសិករយកទៅអនុវត្ត÷***

| ប្រភេទត្រី | រូបមន្តទី១ (%) | រូបមន្តទី២ (%) | រូបមន្តទី៣ (%) | រូបមន្តទី៤ (%) | រូបមន្តទី៥ (%) |
|---|---|---|---|---|---|
| កាបស | 60 (ចម្បង) | 50 (ចម្បង) | 40 | 20 | 20 |
| កាបសាមញ្ញ | 10 | 5 | 5 | 5 | 5 |
| កាបឥណ្ឌា | 25 | 30 | 5 | 5 | 5 |
| កាបស៊ីស្មៅ | 5 | 5 | - | - | - |
| ឆ្ពិន | - | - | - | 40 (ចម្បង) | 30 |
| ត្រីទីឡាព្យា | - | 10 | 50 (ចម្បង) | 30 | 40 (ចម្បង) |
| **សរុប** | **100** | **100** | **100** | **100** | **100** |

**ឧទាហរណ៍÷** ស្រះទំហំ ១,០០០ម² លែងកូនត្រី ៣ក្បាល/ម² សរុបកូនត្រីដាក់ចិញ្ចឹមក្នុងស្រះ ចំនួន ៣,០០០ក្បាល ដោយប្រើរូបមន្តទី២ នាំឱ្យកូនត្រីដែលត្រូវដាក់ចិញ្ចឹមរួមមាន÷

- កូនត្រីកាបស ៥០% ស្មើនឹង ១,៥០០ក្បាល
- កូនត្រីកាបសាមញ្ញ ៥% ស្មើនឹង ១៥០ក្បាល
- កូនត្រីកាបឥណ្ឌា ៣០% ស្មើនឹង ៩០០ក្បាល
- កូនត្រីកាបស៊ីស្មៅ ៥% ស្មើនឹង ១៥០ក្បាល
- កូនត្រីទីឡាព្យា ១០% ស្មើនឹង ៣០០ក្បាល

### ៣.៥. ការលែងកូនត្រីពូជ÷

ក្រោយពីពិនិត្យឃើញថាទឹកមានពណ៌បៃតងខ្ចី កសិករអាចលែងកូនត្រីបាននៅពេលមេឃស្រឡះ និងមានអាកាសធាតុត្រជាក់ (ព្រឹកពីម៉ោង ៨-៩ ឬល្ងាចពីម៉ោង ៤-៥)។ មុនពេលលែងកូនត្រី កសិករត្រូវ ដាក់ថង់ត្រីត្រាំក្នុងស្រះរយៈពេល ១០-២០នាទី ដើម្បីធ្វើឱ្យសីតុណ្ហភាពខាងក្រៅ និងក្នុងថង់ប្រហាក់ ប្រហែលគ្នា និងបន្ថយការនឿយហត់របស់ត្រី។ បន្ទាប់មកត្រូវជួសកូនត្រីពីក្នុងថង់ដាក់ចូលចានដែកដែល មានទឹក១០លីត្រលាយជាមួយអំបិល ០.៣គ.ក ត្រាំរយៈពេល ៥-៦នាទី ដើម្បីព្យាបាលស្នាមរបួស និង កម្ចាត់ពពួកសត្វល្អិតតោងជាប់នឹងដងខ្លួនត្រី។ ក្នុងពេលជួសកូនត្រីពីក្នុងថង់ អ្នកចិញ្ចឹមគួរធ្វើការរាប់ចំនួន កូនត្រី ហើយកត់ត្រាឱ្យបានច្បាស់លាស់។ ក្រោយមកយកកូនត្រីលែងទៅក្នុងស្រះ ដោយបាចទឹកពីខាង ក្រៅចូលទៅក្នុងចានដែកបន្តិចម្តងៗ និងឱ្យកូនត្រីហែលចេញតាមសម្រួល។ មិនត្រូវយកកូនត្រីទៅចាក់

ចូលស្រះភ្លាមៗទាំងបង្ខំនោះទេ ពីព្រោះទឹកក្នុងស្រះ និងក្នុងចានដែកមានសីតុណ្ហភាពខុសគ្នា ដែលកូនត្រីមិនអាចធន់នឹងការប្រែប្រួលសីតុណ្ហភាពយ៉ាងឆាប់រហ័សនោះទេ អាចធ្វើឱ្យត្រីខ្សោយ ឬងាប់បាន។

កុំលែងកូនត្រីនៅពេលមេឃមានភ្លៀង ពីព្រោះទឹកភ្លៀងមានជាតិអាស៊ីតនៅស្រទាប់លើនៃផ្ទៃទឹកក្នុងស្រះអាចធ្វើឱ្យត្រីងាប់បាន។ ករណីមានភ្លៀងកសិករត្រូវរងចាំលែងកូនត្រីក្រោយភ្លៀងរាំងពី ២-៣ម៉ោង ពីព្រោះទឹកនៅក្នុងស្រះបានរលាយជាមួយទឹកភ្លៀងបានច្រើន និងកម្រិតអាស៊ីតចុះទាបដែលកូនត្រីអាចធន់បាន។ ក្រោយពេលលែងកូនត្រីបាន២៤ម៉ោងទើបអាចផ្តល់ចំណីបាន ដើម្បីឱ្យកូនត្រីមានភាពបន្សាំជាមួយទឹកថ្មី និងមានសភាពធម្មតាឡើងវិញ។



### ៣.៦.ប្រភេទចំណី និងការផ្តល់ចំណី÷

**ក-ប្រភេទចំណី÷** មានចំណីបីប្រភេទដែលត្រូវបង្កើត និងផ្តល់ឱ្យត្រីស៊ីរួមមាន÷ ចំណីធម្មជាតិ ចំណីផ្សំដោយខ្លួនឯង និងចំណីសម្រេច/ចំណីគ្រាប់ពីរោងចក្រ។

**-<u>ចំណីធម្មជាតិ</u>÷** រួមមានស្លឹករុក្ខជាតិ រុក្ខជាតិទឹក ចកអាស្វូឡា បន្លែស្លឹក គ្រាប់ធញ្ញជាតិ សត្វល្អិត (កណ្តៀរ ដង្កូវ ជន្លេន ពងអង្ក្រង...) សត្វប្លង់តុង និងរុក្ខជាតិប្លង់តុង ដែលកើតមានដោយសារការដាក់ជីលាមកសត្វ ឬជីគីមីទៅក្នុងស្រះត្រី ពី១-២ដង/ខែ អាស្រ័យទៅលើគុណភាពទឹកក្នុងស្រះ។

**-<u>ចំណីផ្សំដោយខ្លួនឯង</u>÷** ដោយប្រើវត្ថុធាតុដើមខុសៗគ្នាអាស្រ័យទៅតាមតំបន់ មានដូចជា÷ កន្ទក់ ចុងអង្ករ ត្រកួន ចកពងទឹក ចកបាយទា ចកអាស្វូឡា ម្សៅត្រី សណ្តែកសៀង សណ្តែកបាយ បន្លែបៃតង។ ចំណីផ្សំមានស្វនជាគ្រាប់ និងពូនជាដុំ មានតម្លៃទាប ប៉ុន្តែត្រូវកំណត់កម្រិតប្រូតេអ៊ីនឱ្យបានច្បាស់លាស់។ អ្នកចិញ្ចឹមត្រីប្រើប្រាស់ចំណីផ្សំខ្លួនឯងមួយចំនួន យល់ឃើញថា ចំណីមានតម្លៃទាប ប៉ុន្តែមិនបានគិតអំពីសមាមាត្រចំណី (FCR) កម្លាំងពលកម្ម រយៈពេលនៃការចិញ្ចឹម និងការវិភាគសេដ្ឋកិច្ចនៃការចំណាយក្នុង១វគ្គនៃការចិញ្ចឹមបានច្បាស់លាស់ឡើយ។

***តារាងទី៥-រូបមន្តកែច្នៃចំណីផ្សំដោយខ្លួនឯង សម្រាប់ផលិតចំណីទម្ងន់ ១០០គីឡូក្រាម÷***

| លរ | វត្ថុធាតុដើម | រូបមន្តទី១ | រូបមន្តទី២ | រូបមន្តទី៣ | រូបមន្តទី៤ | រូបមន្តទី៥ |
|---|---|---|---|---|---|---|
| 1 | ម្សៅត្រី/កូនត្រីស្ងួត | 10 | - | 5 | 20 | 15 |
| 2 | កន្ទក់ | 70 | 50 | 10 | 40 | 30 |
| 3 | ចុងអង្ករ | 10 | 14 | - | 10 | - |

| | | | | | | |
|---|---|---|---|---|---|---|
| 4 | ម្សៅពោត | - | - | 70 | - | 30 |
| 5 | សណ្តែកសៀង | 10 | 14 | 15 | 30 | - |
| 6 | បន្លែបៃតង | - | 20 | - | - | 25 |
| 7 | អំបិល | - | 2 | - | - | - |
| | **សរុបចំណីផ្សំបាន ១០០គ.ក** | | | | | |

*(រូបមន្តផ្សំចំណីពីកសិករចិញ្ចឹមត្រីជោគជ័យនៅកម្ពុជា និងប្រទេសវៀតណាម)*

ចំណីផ្សំខ្លួនឯងត្រូវចម្អិនឱ្យបានឆ្អិនល្អ ទន់ល្មម និងដាក់ចំណីឱ្យត្រីស៊ីនៅក្នុងកញ្ច្រែងឬធ្នើរដែលទំហំពី ០.៥-១ម$^{២}$។ កញ្ច្រែងឬធ្នើរត្រូវដាក់កម្ពស់ទាបបំផុត ០.៤ម៉ែត្រពីបាតស្រះ និងដាក់នៅទីតាំងច្បាស់លាស់ពី ១-២ទីតាំងក្នុងផ្ទៃស្រះ ១០០ម$^{២}$ ដើម្បីឱ្យត្រីប្រមូលផ្តុំស៊ីចំណីងាយស្រួលក្នុងការពិនិត្យពីសកម្មភាព និងសុខភាពត្រី។

**-<u>ចំណីសម្រេច/ចំណីគ្រាប់រោងចក្រ</u>÷** គឺជាចំណីដែលផលិតពីក្រុមហ៊ុន បានសួនជាគ្រាប់មានកម្រិតប្រូតេអ៊ីន សារធាតុចិញ្ចឹម ទំហំ ការវេចខ្ចប់ ការណែនាំពីវិធីប្រើប្រាស់ និងការរក្សាទុកច្បាស់លាស់។ ជាទូទៅចំណីគ្រាប់មានតម្លៃថ្លៃ ប៉ុន្តែមានការប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការចិញ្ចឹមត្រីបែបឧស្សាហកម្មនាំចេញ និងកសិដ្ឋានធំៗមួយចំនួនក្នុងប្រទេសកម្ពុជា ដោយសារចំណីគ្រាប់មានភាពងាយស្រួលគ្រប់គ្រងថែរក្សា ប្រើប្រាស់ និងសម្រេចលទ្ធផលបានតាមផែនការកំណត់។



**ខ-ការផ្តល់ចំណី÷** ការកំណត់នូវបរិមាណចំណី កម្រិតប្រូតេអ៊ីនក្នុងចំណី ទំហំចំណី និងពេលវេលាផ្តល់ចំណី គឺជាកត្តាសំខាន់ដើម្បីឱ្យត្រីធំធាត់លឿន និងទទួលបានទិន្នផលតាមផែនការកំណត់។ ចំណីដែលត្រូវផ្តល់ឱ្យត្រីស៊ីប្រចាំថ្ងៃត្រូវមានការសិក្សា និងគណនាច្បាស់លាស់។ របៀបនៃការផ្តល់ចំណី និងការគណនាចំណីប្រចាំថ្ងៃរួមមានដូចខាងក្រោម÷

***តារាងទី៦-បច្ចេកទេសនៃការផ្តល់ចំណីត្រី (សម្រាប់ចំណីផ្សំខ្លួនឯង)÷***

| ដំណាក់កាល | %ចំណីធៀបនឹងទម្ងន់ខ្លួនត្រី | ចំនួនដងត្រូវផ្តល់ក្នុង១ថ្ងៃ | ពេលវេលាផ្តល់ចំណី |
|---|---|---|---|
| ខែទី១ | 7-10 | 2 | ផ្តល់ចំណីនៅពេលព្រឹកចន្លោះពីម៉ោង ៦-៧ព្រឹក និងពេលរសៀលពីម៉ោង |
| ខែទី២ | 6-7 | 2 | |

| | | | |
|---|---|---|---|
| ខែទី៣ | 4-5 | 2 | ៥-៦ល្ងាច។ |
| ខែទី៤ឡើងទៅ | 2-3 | 2 | |

សម្រាប់ប្រភេទបន្លែ និងរុក្ខជាតិបៃតងគួរផ្តល់ ២-៣ដង/ សប្តាហ៍ ក្នុងបរិមាណពី ២០-៣០% ធៀបនឹងទម្ងន់ខ្លួនត្រី។ អ្នកចិញ្ចឹមត្រូវត្រួតពិនិត្យកញ្ច្រែងឬធ្នើរដាក់ចំណីជាប្រចាំ ដើម្បីដឹងថាត្រីស៊ីចំណីអស់ឬនៅសល់ និងអាចកំណត់បរិមាណចំណីត្រូវផ្តល់ពេលបន្ទាប់។ ប្រសិនជាពិនិត្យឃើញចំណីនៅសល់ច្រើនបានន័យថាត្រីឆ្អែត ហើយត្រូវកាត់បន្ថយបរិមាណចំណីទៅតាមនោះ។ ប្រសិនជាឃើញទឹកក្នុងស្រះឡើងល្អក់ខុសពីធម្មតា បានន័យថាត្រីឃ្លានហើយត្រូវការបង្កើនបរិមាណចំណី។

***តារាងទី៧- បច្ចេកទេសនៃការផ្តល់ចំណីត្រី (សម្រាប់ចំណីគ្រាប់ពីរោងចក្រ) ÷***

| ទម្ងន់កូនត្រីមធ្យម ក្នុង១ក្បាល | % ចំណីធៀបនឹង ទម្ងន់ខ្លួនត្រី | ចំនួនដង ត្រូវផ្តល់/ថ្ងៃ | កម្រិតប្រូតេអ៊ីន ក្នុងចំណី | ទំហំចំណី (លី) |
|---|---|---|---|---|
| 5-10 ក្រាម | 6 | 3 | 38 | 0.5 |
| 10-30 ក្រាម | 6 | 2/3 | 32 | 1 |
| 30-100 ក្រាម | 5 | 2 | 28/32 | 2 |
| 100-200 ក្រាម | 4.5 | 2 | 24/28 | 3 |
| 200-400 ក្រាម | 3.5 | 2 | 24 | 4 |
| 400-600 ក្រាម | 3 | 2 | 24 | 4 |
| 600-800 ក្រាម | 2.5 | 2 | 24 | 6 |
| 800 ក្រាមឡើងទៅ | 2 | 2 | 20/24 | 6-8 |

❖ **របៀបគណនាចំណីត្រូវផ្តល់ប្រចាំថ្ងៃ÷**

$$\text{បរិមាណចំណីត្រូវផ្តល់ក្នុង១ថ្ងៃ} = \frac{\text{ទំងន់ត្រីសរុប} \times \text{\% ចំណីនៃទម្ងន់ខ្លួនត្រី}}{១០០}$$

**ទម្ងន់ត្រីសរុប** = ទម្ងន់មធ្យមកូនត្រីក្នុង១ក្បាល x ចំនួនត្រីសរុបក្នុងស្រះ

***<u>ឧទាហរណ៍÷</u>*** ស្រះមួយចិញ្ចឹមត្រីកាបសចំនួន ៥,០០០ក្បាល ទម្ងន់ត្រីជាមធ្យមក្នុង១ក្បាល ៦៨ក្រាម។

***តើអ្នកចិញ្ចឹមត្រូវដាក់ចំណីប៉ុន្មានក្នុង១ថ្ងៃ ?***

**ទម្ងន់ត្រីសរុបក្នុងស្រះ** = ៦៨ក្រាម x ៥,០០០ក្បាល = ៣៤០,០០០ក្រាម ឬ = ៣៤០គីឡូក្រាម

$$\text{បរិមាណចំណីត្រូវផ្តល់ក្នុង១ថ្ងៃ} = \frac{៣៤០ \times ៥}{១០០} = \text{១៧គីឡូក្រាម / ថ្ងៃ}$$





**៣.៧.ការគ្រប់គ្រង និងថែទាំ÷** ក្នុងដំណើរការចិញ្ចឹមត្រូវឧស្សាហ៍ត្រួតពិនិត្យមាត់ស្រះ ប្រព័ន្ធបញ្ចេញបញ្ចូលទឹក ស្បៃហ៊ុំស្រះដើម្បីធានាបានសុវត្ថិភាពត្រីចិញ្ចឹម។ ត្រូវពិនិត្យមើលពណ៌ទឹកស្រះជាប្រចាំ ដើម្បីគ្រប់គ្រងបាននូវកម្រិតប្លង់តុងលើស ឬខ្វះ ដែលជាប្រភេទចំណីដ៏សំខាន់របស់ត្រីកាបស។ នៅពេលដែលមានអាកាសធាតុក្តៅខ្លាំង និងអាប់អួរ ត្រីងាយនឹងខ្វះអុកស៊ីសែន បណ្តាលឱ្យត្រីងើបមកលើផ្ទៃទឹក។ ប្រសិនបើពិនិត្យឃើញខ្នងត្រីប្រែទៅជាពណ៌លឿង ហើយបបូរមាត់ខាងក្រោមរីកវែង បញ្ជាក់ថាត្រីស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដែលតម្រូវឱ្យមានការដោះស្រាយជាបន្ទាន់។ ចំណុចសំខាន់ៗមួយចំនួនក្នុងការគ្រប់គ្រង និងថែទាំស្រះចិញ្ចឹមត្រីរួមមានដូចខាងក្រោម÷

**ក-គ្រប់គ្រងលើគុណភាពទឹក÷** ទឹកក្នុងស្រះចិញ្ចឹមត្រីមានពណ៌បៃតងខ្ចី ដែលសម្បូរទៅដោយសារធាតុចិញ្ចឹមធានាបានការលូតលាស់របស់ត្រីបានល្អ។ អ្នកចិញ្ចឹមត្រូវពិនិត្យគុណភាពទឹកមួយដងក្នុង១សប្តាហ៍ អំពីកម្រិត pH និងកម្រិតអាម៉ូញាក់ ($NH_3$)ដែលជាជាតិពុលក្នុងទឹក។ អ្នកចិញ្ចឹមគួរធ្វើការផ្លាស់ប្តូរទឹកពី ២០-៣០%ក្នុង១-២ខែម្តង និងក្រោយពេលប្តូរទឹកគួរបាចកំបោរកសិកម្មចំនួន ១គ.ក/១០០ម៣ទឹក ដើម្បីរក្សាលំនឹងបរិស្ថានទឹកធ្វើឱ្យត្រីលូតលាស់បានល្អ។ នៅពេលមានភ្លៀងខ្លាំង ត្រូវតាមដានកម្រិត pH ទឹកដើម្បីចាត់វិធានការបានសមស្រប។ តាមដានសកម្មភាពរបស់ត្រី ប្រសិនបើម៉ោង ៨ព្រឹកឃើញត្រីងើបឡើងមកលើផ្ទៃទឹក ត្រូវចាត់វិធានការប្តូរទឹក ឬបន្ថែមទឹក។ គ្រប់គ្រងគុណភាពទឹកបានសមស្របតាមលក្ខខណ្ឌនៃការរស់នៅរបស់ត្រី បង្ការបាននូវជំងឺ និងគ្រោះថ្នាក់ជាយថាហេតុលើដំណើរការចិញ្ចឹម។

***តារាងទី៨-ប៉ារ៉ាម៉ែត្រវាស់គុណភាពទឹក÷***

| លរ | ប៉ារ៉ាម៉ែត្រនៃគុណភាពទឹក | កម្រិតសមស្រប |
|---|---|---|
| ១ | សីតុណ្ហភាព | ២៧-៣២ អង្សាសេ |
| ២ | pH | ៧.៥ -៨.៥ |
| ៣ | អុកស៊ីសែន (DO) | >២.២ មីលីក្រាម/លីត្រទឹក |
| ៤ | អាម៉ូញាក់ ($NH_3$) | <០.២ មីលីក្រាម/លីត្រទឹក |
| ៥ | នីទ្រីត ($NO_2$) | <០.៥ មីលីក្រាម/លីត្រទឹក |
| ៦ | កំហាប់អំបិល | ០-២ %/លីត្រទឹក |
| ៧ | កម្រិតថ្លានៃទឹក | ២៥-៤៥ សង់ទីម៉ែត្រ |



**ខ-តាមដានការលូតលាស់របស់ត្រី÷** ការធ្វើសំណាកត្រី(Sampling) រៀងរាល់១ខែម្តងគឺជាមធ្យោបាយល្អបំផុតដើម្បីតាមដានកម្រិតលូតលាស់របស់ត្រី ពិនិត្យសុខភាពត្រី ប៉ាន់ស្មានអត្រារស់ រកមេគុណចំណី (FCR) វាយតម្លៃគុណភាពចំណី និងគណនាបរិមាណចំណីដែលត្រូវផ្តល់ឱ្យត្រីស៊ីបន្ទាប់ទៀត។

***<u>វិធីធ្វើសំណាកត្រី (Sampling)</u>*** ÷ ចាប់ត្រីចន្លោះពី ២០-៥០ក្បាល ដោយប្រើសំណាញ់ ឬឧបករណ៍ផ្សេងៗ នៅពាទីតាំងខុសៗគ្នានៃស្រះ រួចយកត្រីទៅថ្លឹង និងកត់ត្រាពីចំនួន និងទម្ងន់ត្រី។ បន្ទាប់មកគណនារកទម្ងន់ត្រីមធ្យមក្នុង១ក្បាលតាមរូបមន្តខាងក្រោម÷

$$\textbf{ទម្ងន់ត្រីមធ្យមក្នុង១ក្បាល} = \frac{\text{ទម្ងន់ត្រីដែលបានថ្លឹង}}{\text{ចំនួនកូនត្រីដែលបានថ្លឹង}}$$



បង់សំណាញ់ចាប់ត្រីធ្វើសំណាក





ថ្លឹងត្រី រាប់ចំនួនត្រី និងកត់ត្រា

យោងតាមលទ្ធផលនេះ អ្នកចិញ្ចឹមអាចវាយតម្លៃកម្រិតលូតលាស់របស់ត្រីប្រចាំខែ អាចគណនារកទម្ងន់ត្រីសរុបក្នុងស្រះ គណនារកមេគុណ(FCR) និងអាចវាយតម្លៃគុណភាពចំណីដែលកំពុងផ្តល់ឱ្យត្រីស៊ីតាមរយៈការប្រៀបធៀបបរិមាណចំណីដែលបានផ្តល់ជាមួយនឹងការកើនឡើងនៃទម្ងន់ត្រីនៅក្នុងស្រះ។

**រូបមន្តគណនាសមាមាត្រចំណីឬមេគុណចំណី (Feed Conversion Ratio "FCR") ÷**

$$\textbf{សមាមាត្រចំណី/មេគុណចំណី (FCR)} = \frac{\text{ទម្ងន់ចំណីសរុបបានផ្តល់ឱ្យត្រីស៊ី}}{\text{ទម្ងន់ត្រីកើនឡើងក្នុងពេលផ្តល់ចំណី}}$$

## ៣.៨.ការបង្ការ និងការព្យាបាលជំងឺ÷

ជំងឺត្រីគឺជាបញ្ហាចម្បងនៅក្នុងវិស័យវារីវប្បកម្ម ហេតុនេះអ្នកចិញ្ចឹមត្រូវឧស្សាហ៍ពិនិត្យមើលសុខភាពត្រីជាប្រចាំ ដើម្បីគ្រប់គ្រងបានទាន់ពេលវេលា និងកាត់បន្ថយហានិភ័យផ្សេងៗ។

❖ **មូលហេតុដែលនាំឱ្យត្រីកើតមានជំងឺ÷**

-នៅពេលទឹកស្រះកខ្វក់ខូចគុណភាព

-បរិមាណត្រីនៅក្នុងស្រះច្រើនហួសកំណត់

-ការផ្តល់ចំណីមិនបានគ្រប់គ្រាន់ឬលើសកំណត់

-ត្រីត្រូវបានរាតត្បាតដោយពួកប៉ារ៉ាស៊ីត បាក់តេរី ពពួកផ្សិត និងវីរុស... ។ល។

❖ **អាការៈត្រីពេលមានជំងឺ÷**

-ត្រីហែលមិនធម្មតា គ្មានលំនឹង ត្រីបង្ហាញខ្លួននៅលើផ្ទៃទឹកដោយគ្មានទិសដៅ

-នៅពេលព្រឹកព្រលឹម ត្រីងើបឡើងលើផ្ទៃទឹករយៈពេលយូរ ហើយវាស្រូបយកខ្យល់ (ធ្វើមាត់មួបៗ) ពីបរិយាកាស ដោយសារទឹកស្រះខ្វះអុកស៊ីសែន។

-ត្រីមានការប្រែពណ៌សម្បុរ

-ត្រីមិនសូវស៊ីចំណី

-ស្រកា និងព្រុយត្រីមានការដាច់រលាត់

-ស្រកីត្រីប្រែពណ៌ទៅជាស្លាំង

- កើតមានដំបៅនៅលើដងខ្លួន ឬស្រកីត្រី

-ក្រពះ ឬភ្នែកត្រីឡើងហើមប៉ោង

-ផ្នែកខ្លះនៅលើដងខ្លួនមានរបួស និងមានឈាមហូរតិចៗ

-មានរបួសនៅលើក្បាល ពេលខ្លះអាចមើលឃើញឆ្អឹង



**ក/-ការបង្ការជំងឺ÷**

ដោយសារត្រីរស់នៅក្នុងទឹក ធ្វើឱ្យមានការលំបាកក្នុងការស្រាវជ្រាវរកប្រភេទជំងឺ ហើយនៅពេលរកឃើញប្រភេទជំងឺ ការព្យាបាលក៏មានការលំបាក។ ដូច្នេះការការពារជំងឺ គឺប្រសើរជាងការព្យាបាល។ វិធានការបង្ការ/ការពារជំងឺត្រីសំខាន់ៗរួមមាន ÷

-ត្រូវដាក់កូនត្រីចិញ្ចឹមឱ្យសមស្រប មិនត្រូវដាក់ច្រើនពេកទេ

-មុននឹងដាក់កូនត្រីចូលក្នុងស្រះ ត្រូវពិនិត្យឱ្យបានច្បាស់ថា កូនត្រីពូជ ស្រះចិញ្ចឹមត្រីត្រូវបានសម្អាត និងសម្លាប់អស់នូវពពួកសត្វដែលចម្លងមេរោគ។ ត្រូវប្រើកំបោរកសិកម្ម និងជីឱ្យបានត្រឹមត្រូវទៅតាមការណែនាំរបស់អ្នកបច្ចេកទេស។

-ផ្តល់ចំណីដែលមានគុណភាពល្អ និងបរិមាណត្រឹមត្រូវ

-មិនត្រូវឱ្យមានស្លែបៃតងកើតឡើងច្រើនពេកទេ ត្រូវរកវិធីដោះស្រាយ

-រក្សាគុណភាពទឹកឱ្យបានសមស្រប ជាពិសេសកម្រិត pH អាម៉ូញាក់ និងអុកស៊ីសែនរលាយក្នុងទឹក។

-ពេលមានភ្លៀងខ្លាំង សីតុណ្ហភាពទាប ឬអាកាសធាតុប្រែប្រួលលឿន ត្រូវប្រើកំបោរកសិកម្ម ដោយលាយជាមួយទឹកបាចសព្វផ្ទៃស្រះក្នុងបរិមាណ ១-២គ.ក/១០០ម²។





**១/- ជំងឺមួយចំនួនតែងកើតមាននៅលើត្រី÷**

វិធីព្យាបាលមានច្រើនរបៀប ដោយយោងទៅតាមប្រភេទជំងឺ។ នេះគឺជារបៀបសាមញ្ញជាមូលដ្ឋានក្នុងការព្យាបាលជំងឺត្រី÷

*- **ប៉ារ៉ាសិត (Parasite) ÷*** នៅពេលត្រីត្រូវពួកប៉ារ៉ាសិតតោងជាប់នៅលើសារពាង្គកាយ អ្នកចិញ្ចឹមត្រីអាចជ្រើសរើសប្រើវិធីព្យាបាលដូចខាងក្រោមនេះ÷

- ដាក់បន្ទះឫស្សី បន្ទះក្តារ បង្គោលឈើ កំប៉ុង... ឱ្យអណ្តែតលើផ្ទៃទឹកស្រះ នៅក្នុងរយៈពេល២-៣ថ្ងៃម្តងត្រូវប្រមូលវត្ថុទាំងនោះចេញ ហើយហាលថ្ងៃឱ្យស្ងួត ដើម្បីសម្លាប់ពពួកសត្វចម្លងមេរោគដែលតោងជាប់វត្ថុទាំងនោះ រួចដាក់ចូលទឹកវិញ។ ធ្វើដូចនេះ រហូតដល់ពិនិត្យឃើញថាអស់ប៉ារ៉ាសិតពីក្នុងស្រះត្រី។
- អាចប្រើប៉ូតាស្យូមពែរម៉ង់កាណាត ($KMnO_4$) ចំនួនពី២-៤មីលីក្រាមក្នុងមួយលីត្រទឹក (ទឹកស្រះ) ដាក់ចំនួនពីរដងក្នុងមួយសប្តាហ៍ ឬដាក់អំបិលចំនួន ២៥ មីលីក្រាមក្នុងមួយលីត្រ ពី២-៣ដងក្នុងមួយខែ។
- ប្រើកំបោរកសិកម្ម ($CaCo_3$) ចំនួន ២-៣គ.ក/១០០ម² នៃស្រះ





*-ជំងឺក្រហមមាត់ ឬក្រហមលើដងខ្លួន ឬអុជក្រហម÷* ជំងឺនេះបង្កឡើងដោយបាក់តារី *Aeromonas hydrophila* ធ្វើឱ្យត្រីមានអាការៈអត់ស៊ីចំណីឬមិនស៊ីចំណីតែម្ដង ត្រីឡើងមកលើផ្ទៃទឹកហែលដោយគ្មានទិសដៅ មានស្នាមជាំក្រហមនៅលើដងខ្លួន កន្ទុយដាច់រលាត់។ មានវិធីព្យាបាលមួយចំនួនដូចខាងក្រោម÷

- ប្រើប៉ូតាស្យូមពែរម៉ង់កាណាត ($KMnO_4$) ចំនួន ៤មីល្លីក្រាមក្នុងមួយលីត្រទឹកចូលទៅក្នុងទឹកស្រះ។
- ផ្ដល់តេរ៉ាមេស៊ីន (Terramycin, Oxytetracycline) ចំនួនពី ២,៥ទៅ៣,៥ក្រាមក្នុងទម្ងន់ត្រី៥០គីឡូក្រាម លាយជាមួយនឹងចំណីត្រី ព្យាបាលរយៈពេលពី១០ទៅ១៥ថ្ងៃ។
- ប្រើអំបិលពី ២០ ទៅ២៥មីល្លីក្រាមក្នុងមួយលីត្រទឹក ទៅក្នុងទឹកស្រះចំនួន២ដងក្នុងមួយអាទិត្យ រហូតរយៈពេលមួយខែ។




*-ជំងឺថប់ខ្យល់÷* ដោយសារខ្វះអុកស៊ីសែនរលាយក្នុងទឹក នៅពេលដែលអាកាសធាតុមានការប្រែប្រួលលឿន ធ្វើឱ្យត្រីអន់ស៊ីចំណី ឬមិនស៊ីចំណី និងត្រីចាប់ផ្ដើមហែលឡើងមកផ្នែកខាងលើផ្ទៃទឹកស្រូបយកខ្យល់បរិយាកាស(ធ្វើមាត់ម្ហូបៗ)។ ករណីបើដោះស្រាយមិនទាន់ពេលទេនឹងបណ្ដាលឱ្យត្រីងាប់ជាបន្តបន្ទាប់។

**វិធីសាស្ត្រព្យាបាល ឬដោះស្រាយ÷**

- ក្នុងដំណើរការចិញ្ចឹម ត្រូវធ្វើការគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវបរិមាណប្លង់តុងនៅក្នុងស្រះត្រី ផ្ដល់ចំណីឱ្យត្រីស៊ីគ្រប់គ្រាន់ និងគ្រប់គ្រងគុណភាពទឹកឱ្យបានល្អ។
- បង្កើតឱ្យមានអុកស៊ីសែនរលាយក្នុងទឹក ដោយធ្វើឱ្យទឹកស្រះមានចលនាតាមរយៈការបូមទឹកពីបាតស្រះបាញ់ទៅលើ និងទម្លាក់ចូលស្រះវិញបង្កើតទៅជាទឹកសាចមានអុកស៊ីសែនរលាយក្នុងទឹក ឬប្ដូរទឹកពី២០-៣០%។

### ៣.៩.ការប្រមូលផល÷

រយៈពេលចិញ្ចឹមពី ១២ខែ ត្រីកាបសអាចមានទម្ងន់ចន្លោះពី ០.៧-០.៩គីឡូក្រាម/ក្បាល និងអាចប្រមូលផលបាន ដោយផ្អែកលើរដូវខ្សត់ត្រីឬមានតម្រូវការខ្ពស់ឬនៅពេលតម្លៃត្រីនៅលើទីផ្សារឡើងខ្ពស់។

ដោយសារត្រីកាបសជាប្រភេទត្រីមានកម្រិតផ្អើលខ្លាំង នៅពេលប្រមូលផលតែងលោតឡើងផុតពីផ្ទៃទឹក ឬបុកចេញពីអួន។ ដូចនេះអ្នកប្រមូលផលត្រូវមានការប្រុងប្រយ័ត្ន ដោយអូសអួនយឺតសន្សឹមៗ និងត្រូវមានសម្ភារៈសម្រាប់រក្សាទុកត្រី ដើម្បីការពារគុណភាពសាច់ត្រីឱ្យបានល្អ។





## ៤-សេចក្តីសន្និដ្ឋាន

នៅកម្ពុជា ការចិញ្ចឹមត្រីកាបសតែមួយប្រភេទ(ចិញ្ចឹមទោល)ក្នុងស្រះមិនមានចំនួនអ្នកចិញ្ចឹមច្រើននៅឡើយទេ ភាគច្រើនការចិញ្ចឹមត្រីកាបសគឺចិញ្ចឹមចម្រុះជាមួយប្រភេទត្រីផ្សេងទៀតចាប់ពីពមុខឡើងទៅ ពីព្រោះការចិញ្ចឹមត្រីចម្រុះអាចប្រើប្រាស់អស់លទ្ធភាពនូវចំណីដែលមាននៅក្នុងស្រះ និងចំណីដែលបានផ្តល់បន្ថែម។ ត្រូវសិក្សាអំពីបច្ចេកទេសចិញ្ចឹម មានផែនការអាជីវកម្មច្បាស់លាស់ និងមានភាពច្នៃប្រឌិតខ្ពស់ ទើបអាចទទួលបានផលចំណេញល្អប្រសើរ។ កត្តាចម្បងៗមួយចំនួនដែលអ្នកចិញ្ចឹមត្រូវយកចិត្តទុកដាក់មានដូចជា÷ ជ្រើសរើសប្រភេទត្រី និងដង់ស៊ីតេដាក់ត្រីចិញ្ចឹមចម្រុះឱ្យបានសមស្រប ផ្តល់ចំណីត្រីឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។ អ្នកចិញ្ចឹមត្រូវចេះកែច្នៃចំណីផ្សំដោយខ្លួនឯង ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងតំបន់មានតម្លៃទាប ដើម្បីចូលរួមកាត់បន្ថយថ្លៃដើមផលិត។ ត្រូវគ្រប់គ្រង និងថែទាំស្រះចិញ្ចឹមត្រីដោយប្រុងប្រយ័ត្ន ជៀសវាងហានិភ័យកើតឡើងជាយថាហេតុ។ គុណភាពទឹក គឺជាកត្តាកំណត់សុខភាពត្រី ដូចនេះត្រូវពិនិត្យ និងតាមដានគុណភាពទឹកជាប្រចាំ។ អ្នកចិញ្ចឹមត្រូវសិក្សាអំពីបរិមាណ ទម្ងន់ត្រី ពេលវេលាឱ្យបានច្បាស់លាស់មុនពេលដាក់ត្រីចិញ្ចឹម ដើម្បីឱ្យការចិញ្ចឹមសមស្របតាមតម្រូវការទីផ្សារ៕

**ប្រភពឯកសារសិក្សាស្រាវជ្រាវ៖**


- ឯកសារបច្ចេកទេសចិញ្ចឹមត្រីលក្ខណៈគ្រួសារ នៃនាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម រដ្ឋបាលជលផល ឯកសារបំណិនជីវិតស្តីពីកសិកម្ម ផ្នែកទី២ ការចិញ្ចឹមត្រី *https://elibrary.maff.gov.kh/*
- ឯកសារគ្រប់គ្រងសុខភាពកូនត្រី នៃនាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម រដ្ឋបាលជលផល
- សៀវភៅណែនាំស្តីពីវារីវប្បកម្មបែបពាណិជ្ជកម្ម សហការរៀបចំដោយ សាកលវិទ្យាល័យអ៊ំប៊ុន សមាគមសណ្តែកសៀងអាមេរិក និងគម្រោងអភិវឌ្ឍន៍វារីវប្បកម្មសម្រាប់និរន្តរភាពពាណិជ្ជកម្មនៅកម្ពុជា “ខាស់” *(https://www.facebook.com/CASTinCambodia).*
- ឯកសារបច្ចេកទេសចិញ្ចឹមត្រីគម្រោង ហាវេស-វគ្គ១ (Harvest-1)
- *https://en.wikipedia.org/wiki/Silver-carp#cite_note-fishbase-2*
- *https://www.fao.org/fishery/docs/CDrom/FAO_Training/FAO_Training/General/x6709e/x6709e10.htm*
- *https://fishbase.mnhn.fr/summary/Hypophthalmichthys-molitrix.html*
- *https://thefishsite.com/articles/cultured-aquatic-species-silver-carp*
- *https://www.fws.gov/sites/default/files/documents/Ecological-Risk-Screening-Summary-Silver-Carp.pdf*
- *https://www.youtube.com/watch?v=B49OWrCRs38&feature=youtu.be*
- *https://az1368.com/product/ca-me-trang/*
- *https://tepbac.com/tin-tuc/full/huong-dan-cach-nuoi-ca-me-trang-don-gian-cho-nang-suat-cao-34559.html*
- *https://kythuatnuoitrong.edu.vn/nhung-loai-thuc-an-cua-ca-me-trang-1227.html*
- *http://maynhanong.com/index.php*
- Cambodian Mekong Fish: *https://www.facebook.com/profile.php?id=100057288405741*
- Zhao, H.H. (2011). *"Hypophthalmichthys molitrix". IUCN Red List of Threatened Species. 2011*